# សម្បត់ ចូលជាសមាជិក

## ក្នុងក្រុមជំនុំ យូណៃធីតមេថូឌីស្ទ

Mark W. Stamm

DISCIPLESHIP MINISTRIES
The United Methodist Church

# សម្បត់
# ចូលជាសមាជិក

## ក្នុងក្រុមជំនុំ
## យូ៉ណៃធីតមេថូឌីស្ទ

By Mark W. Stamm

សៀវភៅនេះធ្វើឡើងសំរាប់
Discipleship Resources
General Board of Discipleship, 2013

© 2020 Discipleship Resources

Edited by Linda R. Whited and David Whitworth

Translated by Vathanak Heang

Scripture quotations, unless otherwise indicated, are from the New Revised Standard Version of the Bible, copyright © 1989 by the Division of Christian Education of the National Council of the Churches of Christ in the USA. All rights reserved. Used by permission.

OUR MEMBERSHIP VOWS IN THE UNITED METHODIST CHURCH. Copyright © 2002 Discipleship Resources. All rights reserved. No part of this book may be reproduced in any form whatsoever, print or electronic, without written permission, except in the case of brief quotations embodied in critical articles or reviews. For information regarding rights and permissions, contact Discipleship Resources, PO Box 340003, Nashville, TN 37203-0003.

First electronic edition published in 2014 copyright © Discipleship Resources.

# មាតិកា


សេចក្ដីផ្ដើម....................................................................... 4

សម្បត់ដែលចាក់រឹសក្នុងការសន្យានៃពិធីជ្រមុជទឹក .............................. 7

អំណោយទានរបស់ព្រះ........................................................... 7

សម្បត់ធ្វើក្នុងសហគមន៍ ........................................................ 10

គោលការណ៍ដែលមានដូចគ្នានិងក្រុមជំនុំអន្តរនិកាយ ............................ 11

បដិសេធន៍អំពើបាប និងប្រឆាំងអំពើអាក្រក់.......................................... 11

ការប្រកាសទទួលព្រះគ្រីស្ទជាព្រះសង្គ្រោះ ទុកចិត្តដល់ព្រះគុណទ្រង់ និង បម្រើទ្រង់ជាព្រះអម្ចាស់ ...................................................................... 14

តាំងចិត្តជាមួយក្រុមជំនុំ និងព្រះបន្ទូល............................................ 16

សម្បត់ដែលទាក់ទង និងការត្រាស់ហៅជាក់លាក់ណាមួយ ......................... 20

ការត្រាស់ហៅមកបម្រើជាយូណៃធីតមេថូឌីស្ទ...................................... 20

ការត្រាស់ហៅមកបម្រើព្រះគ្រីស្ទ ជាសមាជិកនៃក្រុមជំនុំក្នុងតំបន់ ..................... 23

សំរាប់ការអានផ្សេងទៀត ..................................................... 26

អំពីអ្នកនិពន្ធ........................................................................ 27

# សេចក្តីផ្តើម

ស្វាគមន៍ មកកាន់ការពិភាក្សាគ្នានៃសម្បត់សមាជិក ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ។ ប្រហែលអ្នកពិចារណាចូលជាសមាជិកក្រុមជំនុំនេះ ដោយប្រកាសសេចក្តីជំនឿរបស់អ្នកជាសាធារណៈ។ អ្នកប្រហែលជាប្តូរចេញពី និកាយគ្រីស្ទបរិស័ទផ្សេង ឬប្រហែលអ្នកជាសមាជិកយូណៃធីតមេថូឌីស្ទជាយូរមកហើយ។ ទោះក្នុងករណីណាក៏ដោយ ការគិតពីសម្បត់នេះ ជាការសំខាន់ណាស់ ព្រោះវាអាច អោយយើងស្គាល់នៅគំរោងសំរាប់ការងារបង្កើតសិស្សគ្រីស្ទបរិសទ្ធ។

យោងតាមសៀវភៅវិន័យ នៃក្រុមជំនុំយូណៃធីតមេថូឌីស្ទ សមាជិកសន្យា សំរាប់ដូចខាងក្រោមនេះ។

1. ដើម្បីប្រឆាំងនិងអំណាចនៃសេចក្តីអាក្រក់ បដិសេធន៍អំណាចសាតាំងដែលមានក្នុងពិភពលោកនេះ និងសារភាពបាប។

2. ដើម្បីទទួលបានសេរីភាព និងអំណាចដែលព្រះប្រទានអោយគេ ដើម្បីគេអាចប្រឆាំងការអាក្រក់ ភាពអយុត្តិធម៌ និងការកៀបសង្កត់។

3. ដើម្បីប្រកាសថាព្រះគ្រីស្ទ ជាព្រះសង្គ្រោះ ទុកចិត្តទាំងស្រុងដល់ព្រះគុណទ្រង់ និងសន្យាថាបម្រើទ្រង់ដ៏ជាព្រះ។

4. ដើម្បីបន្តភាពស្មោះត្រង់ជាមួយក្រុមជំនុំបរិសុទ្ធរបស់ព្រះគ្រីស្ទ ហើយបម្រើជាអ្នកតំណាងរបស់ព្រះគ្រីស្ទ ក្នុងពិភពលោក។

5. ដើម្បីស្មោះស្ម័គ្រ ជាមួយព្រះគ្រីស្ទ តាមរយៈក្រុមជំនុំយូណៃធីតមេថូឌីស្ទ ហើយធ្វើការគ្រប់យ៉ាងដែលគេអាចធ្វើបាន ដើម្បីពង្រឹងពន្ធកិច្ចរបស់គេ

6. ដើម្បីចូលរួមក្នុងពន្ធកិច្ចរបស់គេ តាមរយៈការអធិស្ឋាន វត្តមាន អំណោយទាន ការបម្រើ និងស្មរបន្ទាល់

7. ដើម្បីទទួល និងប្រកាសសេចក្តីជំនឿគ្រីស្ទបរិសទ្ធ ដែលមានចែងក្នុងព្រះគម្ពីរ ទាំងសញ្ញាថ្មី និងសញ្ញាចាស់។[1]

[1] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012 (Nashville: រោងពុម្ពយូណៃធីតមេថូឌីស្ទ, 2012), កថាខណ្ឌ 217, ទំព័រ 153. ប្រើដោយមានការអនុញ្ញាតិ

យើងនឹងពិភាក្សាពីចំណុចទាំងនេះម្តងមួយៗ។



សម្បត់សមាជិកភាពនេះ បង្ហាញពីការត្រាស់ហៅរបស់ព្រះ ឲ្យក្លាយជាសិស្ស។ ព្រះអម្ចាស់ ចង់ឲ្យយើងបំពេញការត្រាស់ហៅទាំងនេះ នៅគ្រប់កន្លែងដែលយើងទៅ និងគ្រប់ការដែលយើងធ្វើ។ ដូចជាអ្នកបង្កើតចលនារបស់យើង លោក ចន វេស្លី យើងជឿថា «ពិភពលោកជាក្រុមជំនុំរបស់យើង»[2] ដែលមានន័យថា យើងមិនគួរណាធ្វើរបងជុំវិញទីប្រជុំរបស់យើង និងមិនត្រូវដាក់រនាំង នៅទីដែលយើងត្រូវឈោងចាប់នោះទេ។ ក្រុមជំនុំចូលរួមក្នុងបេសកកម្មរបស់ព្រះ និងជាស្មរបន្ទាល់ ហើយមិនមែនឈប់នៅត្រឹមមាត់ទ្វារក្រុមជំនុំដែរ។ យើងទទួលយកពន្ធកិច្ចទាំងនេះ ទៅកាន់ពិភពលោក ហើយយើងក៏ដឹងដែរថា ការបង្កើតសិស្ស គឺចាប់ផ្តើមចេញពី តំបន់របស់យើង។ យើងត្រូវបានត្រាស់ហៅ អោយបង្ហាញសេចក្តីជំនឿរបស់យើង ក្នុងចំណោមក្រុមជំនុំ និងសហគមន៍ និងក្នុងចំណោមមនុស្សដែលកំពុងជួបបញ្ហា និងក្នុងចំណោមអ្នកដែល ស្គាល់ពីចំនុចខ្សោយរបស់យើង។ កិច្ចការស្រឡាញ់ព្រះ និងមនុស្ស ចាប់ផ្តើមចេញពីការស្រឡាញ់ អ្នកជិតខាង និងសមាជិក្រុមជំនុំរបស់យើង។ សម្បត់សមាជិកភាពនេះ ហៅអោយយើងអនុវត្តន៍ ទាំងក្នុងសកលលោក និងក្នុងតំបន់។

ពេលយើងសូមឲ្យនណាម្នាក់ស្បត់ វារំលឹកយើងថា ការចូលជាសមាជិកក្រុមជំនុំ មានគោលការណ៍ជាក់លាក់។ ជួនកាលយើងចង់បដិសេធន៍ការត្រាស់ហៅនេះ។ តែសូមចាំថា អ្នកមិនមែនទទួលបន្ទុកនេះតែម្នាក់ឯងទេ។ អ្នកស្បត់ជាមួយព្រះគុណរបស់ព្រះ ដោយអ្នកដឹងថា ព្រះវិញ្ញាណបរិសុទ្ធ ផ្តល់កំឡាំងឲ្យអ្នកអាចធ្វើតាមបាន។ សូមនឹកចាំពីកន្លែងដែលអ្នកពូពាក្យសម្បត់នេះ។ ខ្ញុំស្រង់ចេញពីសៀវភៅវិន័យ ព្រោះសម្បត់ជានិតិវិធីក្នុងក្រុមជំនុំរបស់យើង។ តាមផ្លូវច្បាប់ វាសំខាន់ណាស់ក្នុងការដែលយើងរាប់អ្នកណាម្នាក់ជាសមាជិកក្រុមជំនុំ និងការដែលអ្នកនោះចូលជាសមាជិក។ តែមានសមាជិកមេថូឌីស្ទជាច្រើនដែលមិនបានអានសៀវភៅវិន័យ ព្រោះគេ ចង់អានអ្វីដែលមានភាពទាក់ទាញជាង ដូចជារបៀបប្រើម៉ាស៊ីនលៀងចាន ឬបទអធិប្បាយ របស់លោក ចន វេស្លី។ ភាគច្រើន យើងពូពាក្យសម្បត់នេះ ក្នុងកម្មវិធីជ្រមុជទឹក គឺលំអាន នៃពិធីជ្រមុជទឹក ការប្រកាសសេចក្តីជំនឿ ការរំលឹកពិធីជ្រមុជទឹក និង

---

[2] From "Journal from August 12, 1738, to November 1, 1739, " by John Wesley, in The Works of John Wesley, Volume I (Zondervan Publishing House, reproduced from an 1872 edition), page 201.

ការផ្ទេរសមាជិកភាព។[3] នេះជាបរិបទដើម នៃសម្បត់នេះ។ សូមយើងពិចារណាពីអត្ថន័យ និងសារៈសំខាន់ នៃបរិបទពិធីជ្រមុជទឹក។

[3] សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ (Nashville: រោងពុម្ពយូណៃធីតមេថូឌីស្ទ, 1989), ទំព័រ 32-54. សំរាប់ការផ្លាស់ប្តូពិធីដែលតម្រូវដោយមហាសន្និបាទសកលឆ្នាំ 2008 ដែលមានចែងក្នុងសៀវភៅនេះ សូមមើល “New Membership Vows and Ritual (Revised and Corrected)” http://www.gbod.org/lead-your-church/ membership/resource/new-membership-vows-and-ritual-revised-and-corrected Accessed August 29, 2013.

# សម្បត់ដែលចាក់រឹសក្នុងការសន្យានៃពិធីជ្រមុជទឹក

## អំណោយទានរបស់ព្រះ

សារៈសំខាន់ទេវវិទ្យា និងផ្នែកវិញ្ញាណ មានចែងក្នុងកម្មវិធីជ្រមុជទឹកនៃនិកាយយូណៃធីតមេថូឌីស្ទ។ គ្រប់ទាំងការតាំងចិត្តនៃសេចក្តីសន្យាចំពោះព្រះ និងក្រុមជំនុំ ចាក់ឫសក្នុងអំណោយទាននៃ ពិធីជ្រមុជទឹក។ យើងស្រឡាញ់ព្រះ និងស្រឡាញ់គ្នាទៅវិញទៅមក ព្រោះព្រះស្រឡាញ់យើងមុន (យ៉ូហាន ៤៖១០-១១)។ ពេលដែលយើងនាំកូនក្មេងមកទទួលពិធីបុណ្យជ្រមុជទឹក អ្នកធានារបស់គេ នឹងត្រូវប្រកាសពីសម្បត់បីដំបូង (ទំព័រ១)។ បន្ទាប់មក ក្រុមជំនុំទាំងមូល រួមទាំងអ្នកធានាផង ប្រកាសពីសេចក្តីជំនឿគ្រីស្ទបរិសុទ្ធ ដោយអានសេចក្តីជំនឿសាវ័ក។ ចាប់ផ្តើមដោយការអធិស្ឋាន ដោយក្រុមជំនុំនឹកចាំពីសេចក្តីសង្គ្រោះរបស់ព្រះ និងសូមអោយការសង្គ្រោះនេះបន្តតាមរយៈពិធីជ្រមុជទឹក ក្នុងព្រះវិហារ។ រួចធ្វើពិធីជ្រមុជទឹកតែម្តង។ យោងតាមកម្មវិធីរបស់យើង កុមារទាំងនេះ គួរទទួលពិធីលៀងព្រះអម្ចាស់នៅថ្ងៃនោះតែម្តង ទោះបីជាគេមិនទាន់អាចនិយាយពីការតាំងចិត្ត ជួយព្រះគ្រីស្ទ ដោយខ្លួនឯងផ្ទាល់ក៏ដោយ។[4] ជាយូណៃធីតមេថូឌីស្ទ យើងជឿថាកុមារអាច ទទួលពិធីលៀងព្រះអម្ចាស់ជាមួយយើង ដោយទទួលរូបកាយ និងលោហិតព្រះគ្រីស្ទ ដែលធ្វើឲ្យគេ ជាផ្នែកមួយនៃក្រុមជំនុំ (១ កូរិនថូស ១១៖២៣-១២៖៣០)។ យើងហៅកុមារទាំងអស់នេះ ជា «សមាជិក ដែលបានទទួលពិធីជ្រមុជទឹក»។ យើងមិនទាន់ហៅពួកគេថា «សមាជិក ដែលប្រកាសសេចក្តីជំនឿ» ដែលជាអ្នកអាចដឹកនាំក្រុមជំនុំ និងរំពឹងថាជួយក្រុមជំនុំ តាមពន្ធកិច្ចផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ យើងរាប់កុមារទាំងនេះថាជាផ្នែកនៃគ្រួសារព្រះ។[5] តួនាទីនេះ ជា «អំណោយទានរបស់ព្រះ» «ដែលផ្តល់មកយើងដោយមិនគិតថ្លៃ»។[6]

បើអ្នកធានារក្សាសម្បត់របស់គេបានល្អ សមាជិកដែលបានទទួលពិធីជ្រមុជទឹកនេះ នឹងរីក

---

[4] សូមមើលពិធីការក្នុង «សេចក្តីសន្យាពិធីជ្រមុជទឹកII, ពិធីជ្រមុជទឹកសម្រាប់កុមារ និងអ្នកដែលមិនអាចឆ្លើយសំនួរបានដោយខ្លួនឯង» សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ (Nashville: រោងពុម្ពយូណៃធីតមេថូឌីស្ទ, 1989), ទំព័រ 43.

[5] "By Water and the Spirit: A United Methodist Understanding of Baptism," The Book of Resolutions of the United Methodist Church, 2012 (Nashville: រោងពុម្ពយូណៃធីតមេថូឌីស្ទ, 2012), ទំព័រ 937-38. ប្រើដោយមានការអនុញ្ញាត។ សូមមើល សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012. (Nashville, Tennessee: រោងពុម្ពយូណៃធីតមេថូឌីស្ទ, 2012), កថាខណ្ឌ214-26.

[6] សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ ទំព័រ៣៩។ Baptismal Covenant I from Baptismal Covenants I, II ©1976, 1980, 1985, 1989, រោងពុម្ពយូណៃធីតមេថូឌីស្ទ.



ធំធាត់ ឡើងក្នុងបរិបទនៃជីវិតក្រុមជំនុំ ដែលគេនឹងរៀនពីរឿងក្នុងព្រះគម្ពីរ នឹងអភិវឌ្ឍន៍ជីវិតនៃការអធិស្ឋាន និងការបំរើ។ យើងសង្ឃឹមថា គេយល់ថាព្រះគម្ពីរជារឿងនៃគ្រួសាររបស់គេ ការអធិស្ឋាន និងការបម្រើ គឺជាផ្លូវនៃជីវិតរបស់គេ។ យើងសង្ឃឹមថាពួកគេនឹងមកទទួលពិធីលៀងព្រះអម្ចាស់ ដែលគេរៀនពីការអរព្រះគុណ និងការទទួលអំណោយទានរបស់ព្រះ។ យើងសង្ឃឹមថា បទពិសោធន៍នៃការថ្វាយបង្គំជាក្រុម នឹងជួយអោយគេមានប្រាជ្ញាមកពីព្រះ ក្តីមេត្តាករុណា និងភាពយុត្តិធម៌។ យើងជឿថា នៅពេលណាមួយ គេនឹងរីកចំរើន ហើយអាចធ្វើការប្រកាសជំនឿ និងទទួលយកសម្បត់ដែលអ្នកធានារបស់គេបានធ្វើ និងធ្វើសម្បត់សមាជិកភាពនៃក្រុមជំនុំរបស់គេ (ទំព័រ ២៤-២៧)។ ទោះជាពេលដែលគធ្វើសម្បត់ទាំងនោះ គេនឹងត្រូវបានរំលឹកពីការធ្វើតាមសម្បត់ ដែលចាក់ឬសក្នុងព្រះគុណរបស់ព្រះ។

រាល់សម្បត់របស់យើងចាក់រឹសក្នុងព្រះគុណ ដែលបានផ្តល់មកតាមរយៈពិធីជ្រមុជទឹក។ ក្នុងពេលណាមួយ ប្រហែលមានអ្នកដែលថ្វាយខ្លួនពេលនេះចំនួនពីរនាក់ នឹងត្រលប់មកកាន់អាស្នាក្រុមជំនុំ យូណៃធីតមេថូឌីស្ទ ដើម្បីប្តូរសម្បត់អាពាហ៍ពិពាហ៍។ ថ្ងៃណាមួយ ពិធីនេះនឹងរំលឹកពួកគេថា គេ «ចូលក្នុងសម្ព័ន្ធមេត្រីតែមួយតាមរយៈព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ... ដែលទទួលស្គាល់ក្នុងពិធីបុណ្យជ្រមុជទឹករបស់អ្នក។»[7] ប្រហែលថ្ងៃណាមួយ មានម្នាក់ក្នុងចំណោមពួកគេ ឮការត្រាស់ហៅអោយចូលមកក្នុងពន្ធកិច្ចចាក់ប្រេងតាំង ហើយចាប់ផ្តើមដំណើរការគិតពិចារណា និងរៀបចំខ្លួនចូលក្នុងពិធីចាក់ប្រេងតាំងនៃមហាសន្និបាតប្រចាំឆ្នាំ។ មុនពេលដែលគេទទួលបានប្រេងតាំង លោកអភិបាលនឹងរលឹកគេ និងក្រុមជំនុំទាំងមូល ឲ្យចាំពី «ពិធី

[7] “ពិធីអាពាហ៍ពិពាហ៍គ្រីស្ទបរិសទ្ធ” ពីសៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ ទំព័រ៨៦៥ © 1989, រោងពុម្ពយូណៃធីតមេថូឌីស្ទ

ជ្រមុជរបស់អ្នក និងការអរព្រះគុណ»[8] ។ ពិតណាស់ ពិធីជ្រមុជ គឺជាគ្រឹះសំរាប់គ្រប់អំណោយទាននៃពន្ធកិច្ច។ ពេលដែលគេណាម្នាក់ស្លាប់ ក្រុមគ្រួសារ និងមិត្តភក្រ័ និងក្រុមជំនុំទាំងមូល នឹងត្រូវបានរំលឹកពីសេចក្តីសង្ឃឹមអស់កល្ប ដែលមិនមែនមានក្នុងបញ្ជីរនៃការដែលគេបានធ្វើ តែមានក្នុងអំណោយទាន របស់ព្រះ ដែលបានប្រទានឲ្យដោយឥតគិតថ្ក្នុងពិធីជ្រមុជ។ ពេលយើងថ្វាយសព្វទៅកាន់ ព្រះក្នុងពិធីបញ្ចុះសព្វ យើងនិយាយថា «ដូចក្នុងពិធីជ្រមុជ យើងបានថ្វាយគាត់ដល់ព្រះគ្រីស្ទ ដូច្នេះ ក្នុងព្រះគ្រីស្ទ សូមអោយគាត់បានគ្របដណ្តប់ដោយសិរីល្អទ្រង់។»[9]

ការធ្វើសម្បត់សមាជិកភាព ក្នុងបរិបទនៃសេចក្តីសន្យាពិធីជ្រមុជទឹក រំលឹកយើងថា គ្រប់ការតាំងចិត្តគ្រីស្ទបរិសទ្ធ ចាក់ឬសក្នុងព្រះគុណរបស់ព្រះ។ យើងទទូចថា មនុស្សមិនគ្រប់លក្ខ័ណទំនាក់ទំនងរបស់យើងរញ៉េរញ៉ៃ យើងមិនបានអរគុណចំពោះអ្វីដែលយើងមាន យើងច្រណែនចំពោះអ្វីដែលយើងអត់មាន។ យើងបំផ្លាញកេរ្តិ៍ដំណែលរបស់យើង រួមមានទាំងគ្រាប់ទាំងរបស់សព្វសារពើរដែលទ្រង់បង្កើត ហើយថែមទាំងព្រះនាមទ្រង់ទៀតផង។ ទោះយើងខំយ៉ាងណាក៏ដោយ ការខំដោះស្រាយបញ្ហាទាំងនោះ បរាជ័យទៅវិញ។ ជួនកាល យើងធ្វើឲ្យបញ្ហាទាំងនោះកាន់តែអាក្រក់។ ដូចជាសវក្សប៉ុលបានសរសេរ «ខ្ញុំមិនយល់ពីសកម្មភាពរបស់ខ្ញុំទេ។ ខ្ញុំមិនធ្វើអ្វីដែលខ្ញុំចង់ធ្វើ តែខ្ញុំធ្វើអ្វីដែលខ្ញុំស្អប់» (រ៉ូម ៧៖១៥)។ តែយើងមិនបោះបង់ចោលអោយអស់សង្ឃឹមនោះទេ។ ដែលយើងតាមលោក ចន វេស្លី យើងជាមេថូឌីស្ទ ជឿលើព្រះគុណដំបូង ដែលមានន័យថា ព្រះគុណដែលផ្តល់អោយយើងតាំងពីមុន ដែលធ្វើឲ្យការបង្កើតសិស្សកើតមានឡើង។ យើងទទួចថា ព្រះវិញ្ញាណកំពុងធ្វើការ នាំយើងនិងអ្នកដទៃមកចំពោះព្រះ ដាំសុបិន្តបរិសុទ្ធក្នុងចិត្តយើង។ យើងមានសេរី ដើម្បីទទួលបានព្រះគុណ តែបើយើងសហការណ៍ជាមួយព្រះ ក្នុងជីវិតរបស់យើង ការល្អជាច្រើនអាចកើតឡើង។ ដូច្នេះយើងជឿថា យើងអាចរក្សាសម្បត់សមាជិកភាពនេះបាន ប៉ុន្តែយើងដឹងថា យើងធ្វើការនេះដោយសេចក្តីមេត្តាករុណារបស់ព្រះ និងសេចក្តីអធិស្ឋានដោយជំនឿ របស់ក្រុមជំនុំ។

---

[8] ពិធីពន្ធកិច្ចក្រុមជំនុំយូណៃធីតមេថូឌីស្ទ, 2013-2016 ដែលយល់ព្រម និងកែសម្រួល ដោយមហាសន្និបាទសកលឆ្នាំ 2012 រៀបចំដោយ The General Board of Discipleship, The General Board of Higher Education and Ministry and The General Commission on Christian Unity and Inter-religious Concerns in collaboration with The Council of Bishops. (Nashville, Tennessee: The United Methodist Publishing House, 2012), 20. http:// www.gbod.org/content/uploads/2013-2016OrdinalFINAL.pdf Accessed August 29, 2013.

[9] “ពិធីបុណ្យសព្វនិងការរស់ឡើងវិញ” ពីសៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, 870, ©1989 រោងពុម្ពយូណៃធីតមេថូឌីស្ទ

# សម្បត់ធ្វើក្នុងសហគមន៍

យើងត្រូវការសេចក្តីអធិស្ឋានទាំងនេះ។ ដែលយើងធ្វើសម្បត់សមាជិកភាពនេះ ក្នុងបរិបទនៃការ សន្យានៃពិធីជ្រមុជទឹក ដែលរំលឹកយើងថា យើងមិនមែនធ្វើការនេះដោយម្នាក់ឯងនោះទេ តែយើងធ្វើជាមួយអ្នកដទៃ។ យូណៃធីតមេថូឌីស្ទយល់ថា ពិធីជ្រមុជទឹក ធ្វើឡើងក្នុងបរិបទ នៃកម្មវិធីថ្វាយបង្គំក្នុងព្រះវិហារ។ ពាក្យសម្បត់ធ្វើនៅទីសាធារណៈ មានគ្រីស្ទបរស័ទដទៃទៀតជាសាក្សី ហើយគេត្រូវបានសូមអោយជួយគាំពារ សមាជិកថ្មី ក្នុងពេលដែលសមាជិកថ្មីនេះ និងធ្វើដូចគ្នាដែរ។ សមាជិកក្រុមជំនុំស្បត់ឡើងវិញ។

ក្រុមជំនុំមួយចំនួន ផ្តល់វិធីផ្សេងទៀត ដែលធ្វើជាលក្ខណៈឯកជន ក្នុងការស្បត់ចូលជាសមាជិកក្រុមជំនុំ ប៉ុន្តែ មើលទៅដូចជាមិនទំនង។ បរិបទពិធីជ្រមុជទឹក សម្បត់របស់គ្រីស្ទបរិស័ទគួរធ្វើក្នុងទីសាធារណៈ អោយក្រុមជំនុំទាំងមូលឃើញ។ នេះមានន័យថាយើងចូលរួមក្នុងការងារព្រះតាមរយៈសាក្សីរបស់យើង។ ការប្រកាសជាសាធារណៈអាចពិបាក ឬគ្រោះថ្នាក់ តែក្រុមជំនុំសន្យាថា នឹងជួយការពារយើង និងធ្វើជាអ្នកជំនួយដែលចាំជួយលើកទឹកចិត្តដល់យើង (ហេព្រើរ ១២៖១-២).

ពិធីជ្រមុជទឹក មានប្រវត្តិ និងឫសគល់ ជាអន្តរនិកាយ ដែលរំលឹកយើងថា យើងស្បត់ចូលក្នុងសហគមន៍គ្រីស្ទបរិសទ្ធ ពីអតីតកាល និងជាមួយបងប្អូនប្រុសស្រី ក្នុងសាខានៃក្រុមជំនុំជុំវិញពិភពលោក។ ពេលនេះយើងនឹងបែរចំណាប់អារម្មណ៍របស់យើងចំពោះសម្បត់ទាំងនេះ ដែលបង្ហាញពីកេរ្ត៍ដំណែលគ្រីស្ទបរិសទ្ធរបស់យើង។

# គោលការណ៍ដែលមានដូចគ្នានិងក្រុមជំនុំអន្តរនិកាយ

## បដិសេធន៍អំពើបាប និងប្រឆាំងអំពើអាក្រក់

សម្បត់សមាជិកភាពពីរដំបូង និយាយពីបញ្ហាអំពើបាប និងអំពើអាក្រក់។ សមាជិកតម្រូវឲ្យធ្វើដូចខាងក្រោម៖

> បដិសេធន៍អំណាចនៃវិញ្ញាណអាក្រក់ បណ្ដេញអំណាចនៃអំពើអាក្រក់ក្នុងពិភពលោកនេះ និងសារភាពបាប និង
>
> ទទួលសិរីភាព និងអំណាចដែលព្រះប្រទានអោយពួកគេដើម្បីប្រឆាំងអំពើអាក្រក់ ភាពអយុត្តិធម៌ និងការកៀបសង្កត់។[1]

បើតាមលំដាប់លំដោយក្រុមជំនុំសម័យមុន ដែលគេហៅថា ទម្លាប់សាវក្យ ដែលចាក់រឹស «តាំងពីសតវត្សទីពីរ»[11] ពេលដែលអ្នកណាម្នាក់ចង់ចូលជាសមាជិកព្រះវិហារ តាមពិធីជ្រមុជទឹក យន្តការនៃពិធីជ្រមុជ គឺចាប់ផ្តើមចេញពីការសារភាពបាប។ អ្នកចម្បាំង អ្នកថ្វាយបង្គំរូបព្រះ អ្នកកំផិត និងអ្នកផ្សេងទៀត ត្រូវបានបង្គាប់អោយលះបង់ទំលាប់អំពើបាបរបស់គេភ្លាម ឬមិនអញ្ចឹងទេ គេអាចត្រលប់មកសារជាថ្មី ពេលគេត្រៀមខ្លួនរួចរាល់។[12] ចំពោះលោក John Wesley ក្នុងសត្តវត្សទី១៨ គាត់ក៏បានទាមទារស្រដៀងគ្នានេះដែរ សំរាប់អ្នកដែលចង់ក្លាយជាសមាជិកមេថូឌីស្ទ។ ទោះជាមេថូឌីស្ទ សម័យដើមមិនមានសម្បត់សមាជិកភាពមែន តែគេមាន «ច្បាប់ទូទៅ» ហើយច្បាប់នោះត្រូវឲ្យអ្នករាល់គ្នាដើរតាម «ដើម្បីឲ្យគេអាចរួចផុតពីសេចក្តី វិនាស ហើយឲ្យមកទទួលបានសេចក្តីសង្គ្រោះពីអំពើបាបរបស់គេ។»[13] ច្បាប់ទីមួយ តម្រូវឲ្យសមាជិកមិនធ្វើការអាក្រក់ និងជៀសវាងការអាក្រក់គ្រប់បែបយ៉ាង។ លោក វេស្លី បានហៅការអាក្រក់មួយចំនួន

---

[10] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ, 2012, កថាខណ្ឌ 217, ទំព័រ 153. ប្រើដោយមានការអនុញ្ញាតិ

[11] Paul F. Bradshaw, Maxwell E. Johnson, and L. Edward Phillips. The Apostolic Tradition, A Commentary.  Edited by Harold W. Attridge (Minneapolis, Minnesota: Fortress Press, 2002), 14.

[12] Ibid., 88-93.

[13] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012, កថាខណ្ឌ 103, ទំព័រ 72. ប្រើដោយមានការអនុញ្ញាតិ

ដូចជា មានទាសករ ចងការប្រាក់ ការសន្ទនាដែលមិនសមរម្យ។[14] តារាងនេះមិនទាន់និយាយអស់នោះទេ តែវាបង្ហាញពីការជាក់លាក់មួយចំនួន ដែលទាក់ទងទៅការសារភាពបាប។

អ្នកខ្លះគិតថា ការនិយាយពីអំពើបាប និងការអាក្រក់ ស្តាប់ទៅដូចជាកាត់ទោសពេក ប៉ុន្តែមតិភាគច្រើនគិតថា ការបដិសេធន៍អំពើបាប និងការអាក្រក់ គឺជាគ្រឹះនៃការងារក្រុមជំនុំ។ ពិធីជ្រមុជទឹក តាំងពីសម័យដើម និងសម័យនេះ មានសម្បត់ស្រដៀងគ្នា ខ្លះវាសាំញ៉ាំជាងនេះទៀត។ ឧទាហរណ៍ ពិធីរបស់កាតូលិក ដែលហៅថា Christian Initiation of Adults (RCIA) ទាមទារអោយមានការសង្កេតយ៉ាងហ្មត់ចត់ នៅថ្ងៃអាទិត្យទី៣ ទី៤ និងទី៥ នៃរដូវ Lent។ ក្នុងពិធីនេះ សមាជិកក្រុមជំនុំអធិស្ឋានថា អ្នកដែលត្រៀមខ្លួនជ្រមុជទឹក មានសិរីភាពពីនៃសេចក្តីជំនឿក្នុងព្រះគ្រីស្ទ។[15]ការសង្កេតនេះគឺជាទំលាប់នៃការដេញវិញ្ញាណអាក្រក់ក្នុងព្រះវិហារសម័យដើម។ បើការសង្កេតនេះធ្វើតាមរបៀបត្រឹមត្រូវ ដោយគ្មានបើកសំដែងចំលែកៗ វាជាការទទួលស្គាល់អំពើបាប និងអំពើអាក្រក់ ដែលក្រុមជំនុំនិងត្រូវដោះស្រាយដោយសេចក្តីអធិស្ឋាន។

បន្ទាប់ពីសត្តវត្សទី២០ដ៏កាចសាហាវ ដែលមានសង្គ្រាមលោកពីរដង និងការប្រល័យពូជសាសន៍មួយចំនួន យើងច្បាស់ជាយល់ និងទទួលស្គាល់ អំណាចនៃអំពើអាក្រក់។ ប្រវត្តិសាសន៍ថ្មីៗនេះ ដែលនិយាយពីភារវកម្ម ការវាយប្រហារថ្ងៃ១១ ខែកញ្ញា ឆ្នាំ២០០១ និងការបំផ្ទុះគ្រាប់បែកនៅឆ្នាំ១៩៩៥ នៅទីក្រុង Oklahoma បញ្ជាក់កាន់តែច្បាស់ ពីអំណាចនៃអំពើអាក្រក់។ ក៏ដូចជាការបៀតបៀនកេរ្តិ៍ភេទកុមារ ដោយមនុស្សដែលអ្នកផងស្មានថាមនុស្សល្អ។ អំពើបាប និងអំពើអាក្រក់ សំឡាប់មនុស្ស ធ្វើអោយប្រឡាក់ប្រឡូសចំពោះការបង្កើតរបស់ព្រះ និងប្រឆាំងទស្សនៈវិស័យ នៃរាជ្យរបស់ព្រះ។ ការដែលយើងធ្វើមិនដឹងមិនឮ
គឺជាការដែលយើងយល់ស្របអោយការនេះ កើតឡើង ដូច្នេះហើយបានជាកូនរបស់ព្រះ ត្រូវតែហៅអំពើបាបនិងអំពើអាក្រក់ឲ្យចំឈ្មោះ ដើម្បីយើងអាចបដិសេធន៍ និងប្រឆាំងវា។

តើក្រុមជំនុំធ្វើការប្រឆាំងនេះ យ៉ាងដូចម្តេចទៅ? តើវិធីរបស់យើងខុសពីវិធីរបស់អ្នក ដែលនៅខាងក្រៅក្រុមជំនុំទេ? ពេលដែលជនជាតិអាមេរិក គិតអំពីការប្រឆាំងអំពើរអាក្រក់ ខួរក្បាលរបស់យើងគិតទៅដល់ការប្រឆាំងពួក Nazi ដោយបញ្ជូនកងទ័ពក្មេងៗ ទៅច្បាំងនៅ Normandy។ យើងប្រហែលជាគិតពីប៉ូលីស និងអ្នកពន្លត់អគ្គីភ័យ នៅទីក្រុង New York ដែលរត់ចូលទៅក្នុងអាគារ World Trade Center ដែលជាការលះបង់ជីវិតរបស់គេ ដើម្បីសង្គ្រោះជីវិតអ្នកដទៃ។ សកម្មភាពទាំងនេះបាននិយាយថា «ទេ» ចំពោះការអាក្រក់។ អ្នកដែលបំរើ មើលឃើញថាការងាររបស់គេ គឺជាការបង្ហាញពីភាពជាសិស្សរបស់ព្រះគ្រីស្ទ។ ទោះជាមានការលើកទឹកចិត្តបែបណាក៏ដោយ ជីវិតត្រូវបានសង្គ្រោះដោយសារការលះបង់ទាំងនេះ ហើយនេះឯងជាអំពើល្អ។

---

[14] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012, កថាខណ្ឌ 103, ទំព័រ 73.

[15] Rite of Christian Initiation of Adults, study edition (Chicago: Liturgy Training Publications, 1988), ទំព័រ 80-87, 94-109.

ការប្រឆាំងអំពើអាក្រក់អាចទាមទារអោយប្រើកំឡាំង។ ហេតុផលនេះហើយ ក្រុមជំនុំត្រូវតែគិតពីការប្រើកំឡាំងយុត្តិធម៌ ហើយក្រុមជំនុំយើងបានធ្វើការនេះហើយ។ ដូចជា គោលការណ៍សង្គមរបស់មេថូឌីស្ទយើងចែងថា «យើងប្រឆាំងសង្គ្រាម ហើយជំរុញអោយមានសន្តិភាពសម្រាប់រាល់ជម្លោះទាំងឡាយរវាងប្រទេសផ្សេងៗ។» យើងរំលឹក ខ្លួនឯងថា គ្រីស្ទបរិសទ្ធជាច្រើន បានសំរេចចិត្តថា ការប្រើកំឡាំង «អាចធ្វើទាំងបង្ខំ ដើម្បីប្រឆាំងចំពោះការឈ្លៀនពានអំណាចផ្តាច់ការ និងការប្រល័យពូជសាសន៍។»[1]




ប៉ុន្តែយើងមិនបានឮដំណឹងល្អ បើយើងគិតថា អំណាចនេះជាវិធីតែមួយដែលអាច ប្រឆាំងអំពើរអាក្រក់។ បរិបទសំណោរ និងសម្បត់សមាជិកភាព ប្រាប់ពីវិធីមួយទៀត។ យោងតាមក្រុមជំនុំពីដើម ដែលយើងបាននិយាយពីមុន បន្ទាប់ពីទទួលពិធីជ្រមុជទឹករួចហើយ សមាជិកចូលជំនុំគ្នា ដែលគ្រប់គ្នាអាចអធិស្ឋានចែករំលែកសន្តិភាព និងទទួលពិធីលៀងព្រះអម្ចាស់។[17] ពិធីនេះបង្ហាញថា ពិធីជ្រមុជទឹកនិងកម្មវិធីថ្វាយបង្គំទាំងនេះ ទាក់ទងគ្នាយ៉ាងខ្លាំង។ ការអធិស្ឋានគឺជាវិធីមួយប្រឆាំងនិងអំពើអាក្រក់។ ពេលដែលក្រុមជំនុំ ធ្វើការប្រកបគ្នាដោយការចែករំលែកសន្តិភាព នោះអំពើអាក្រក់ ត្រូវបានដកទាំងឬស មុនពេលដែលវាអាចកើតទៅជា អំពើហឹង្សា។ ពេលក្រុមជំនុំទទួល ពិធីលៀងព្រះអម្ចាស់ ថ្វាយខ្លួន និងថ្វាយដង្វាយដល់ព្រះអម្ចាស់ ដោយការអរព្រះគុណសំរាប់កិច្ចការអស្ចារ្យ ក្នុងព្រះយេស៊ូវគ្រីស្ទ នោះគេកំពុងរៀនពីការគ្រប់គ្រងលើការបង្កើតរបស់ព្រះ ដោយត្រឹមត្រូវ។ ពេលដែលចំណិតនំប៉ុង និងទឹកទំពាំងបាយជូ ត្រូវបានឲ្យ និងទទួលដោយឥតគិតថ្លៃ នោះអំណាចនៃភាពអត្មានិយមត្រូវបានកំទេច ហើយទស្សនៈនៃសហគមន៍ បានកើតឡើង។ ពិធីលៀងព្រះអម្ចាស់ប្រឆាំងនិងអំពើអាក្រក់ ដោយការកែទម្រង់យើងទាំងអស់គ្នា ឲ្យមានទស្សនៈថ្មី។

---

[16] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ, 2012 (Nashville, Tennessee: រោងពុម្ពយូណៃធីតមេថូឌីស្ទ, 2012), កថាខណ្ឌ164.l, ទំព័រ 138. ប្រើដោយមានការអនុញ្ញាតិ

[17] Paul F. Bradshaw, Maxwell E. Johnson, and L. Edward Phillips. The Apostolic Tradition, A Commentary.  Edited by Harold W. Attridge (Minneapolis, Minnesota: Fortress Press, 2002), 120-23.

សកម្មភាពតាមសំណេរនេះ នឹងធ្វើឲ្យជីវិតយើងកែប្រែ ទាំងក្នុងក្រុមជំនុំ និងក្នុងសហគមន៍ និងពិភពលោក។ ដែលយើងឮព្រះបន្ទូល យើងក្លាយជាអ្នកនិយាយពីសេចក្ដីពិត និងសេចក្ដីស្រឡាញ់។ តាមរយៈការជួយអ្នកក្រ យើងក្លាយជាអ្នកអធិស្ឋាន ដោយដៃ និងជើង។ តាមរយៈការចែករំលែកសន្តិភាព យើងនឹងរស់នៅ ដោយសន្តិភាព ជាមួយអ្នកជិតខាង។ តាមរយៈការទទួលពិធីលៀងព្រះអម្ចាស់ យើងរៀនពីការអរព្រះគុណ សំរាប់គ្រប់ទាំងអំណោយទានរបស់ព្រះ។ សក្ខីកម្មទាំងនេះ ចាក់ឫសក្នុងការថ្វាយបង្គំ និងប្រឆាំងអំពើអាក្រក់ បញ្ឈប់ការអាក្រក់ទាំងនេះ កុំឲ្យវាធំធាត់។

## ការប្រកាសទទួលព្រះគ្រីស្ទជាព្រះសង្គ្រោះ ទុកចិត្តដល់ព្រះគុណទ្រង់ និង បម្រើទ្រង់ជាព្រះអម្ចាស់

ការដែលយើងនិយាយពីអំពើបាប និងអំពើអាក្រក់ សម្បត់ទីបី បង្គាប់ឲ្យយើង បែរកព្រះយេស៊ូវគ្រីស្ទ។ សមាជិកត្រូវបានបង្គាប់ឲ្យ «ទទួលព្រះគ្រីស្ទជាព្រះសង្គ្រោះ ទុកចិត្តដល់ព្រះគុណទ្រង់ និង បម្រើទ្រង់ជាព្រះអម្ចាស់»។[18] ពិតណាស់ ដែលថាការដែលយើងបែរចេញពីអំពើបាប និងបែរទៅរកព្រះគុណ មិនមែនជាការដែល យើងធ្វើតែម្ដង ដោយមិនមានការធ្វើឡើងវិញនោះទេ។ ពាក្យថា «ប្រកាស» មានន័យច្រើនជាងគ្រាន់តែស្គាល់ដំណឹងល្អ។ វាមានន័យថា យើងត្រូវនិយាយការពិតដោយឮៗ ទាំងពាក្យសម្ដី និងសកម្មភាព។ សាវក្យប៉ុលបាននិយាយថា

> «ព្រះបន្ទូលនៅជិតឯង ក៏នៅក្នុងមាត់ ហើយក្នុងចិត្តឯងផង នោះគឺជាព្រះបន្ទូល នៃសេចក្តីជំនឿ ដែលយើងខ្ញុំកំពុងតែប្រកាសប្រាប់ថា បើមាត់អ្នក នឹងទទួលថ្លែង ប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត។ ដ្បិតយើងបានសុចរិតដោយសេចក្តីជំនឿ ហើយក៏បានសង្គ្រោះ ដោយមាត់ទទួលថ្លែងប្រាប់។»

ការប្រកាសនេះជាសញ្ញាថាយើងនៃមនុស្សនៃសេចក្ដីសន្យា ហើយអត្តសញ្ញាណនេះ អាចជាការប្រថុយប្រថាន ព្រោះថាការហៅព្រះយេស៊ូវគ្រីស្ទ ថា «ព្រះអម្ចាស់» មានន័យថាគ្មានអ្នកណាផ្សេងជា «ព្រះអម្ចាស់»។ អ្នកខ្លះទទួលរងគ្រោះ ដូចជា លោក Maximus "The Confessor" (ក្នុងឆ្នាំ ៥៨០-៦៦២) ដែលជាអ្នកការពារគោលលិទ្ធិរបស់ព្រះគ្រីស្ទ ប្រឆាំងនិងគោលលិទ្ធិខុសឆ្គង របស់ Constantinople (Pyrrhus). តាមកំណត់ហេតុការកាត់ទោស គេបានកាត់

---

[18] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ, 2012, កថាខណ្ឌ 217, ទំព័រ 153. ប្រើដោយមានការអនុញ្ញាតិ

អណ្ដាត និងដៃរបស់លោក Maximus។[19] ស្រដៀងគ្នានេះដែរ គ្រីស្ទានជនជាត់អាឡឺម៉ង់ភាគតិច ដែលហៅក្រុមខ្លួងឯងថា «ក្រុមជំនុំប្រកាស» ដែលប្រឆាំងរបបលោក អ៊ីត្លែ។ ពួកគេប្រកាសពីព្រះគ្រីស្ទសាធារណៈ ដោយដឹងថាគេអាចមានគ្រោះថ្នាក់។ លោក Dietrich Bonhoeffer ដែលជាវិរៈបុរសរបស់ពួកគេ រំលឹកយើងថា ពេលដែលអ្នកណាម្នាក់ ទទួលបានការត្រាស់ហៅពីព្រះគ្រីស្ទ នោះជាការត្រាស់ហៅទៅរកសេចក្ដីស្លាប់។[20]

ភាគច្រើន ការប្រកាសទទួលព្រះគ្រីស្ទរបស់យើង មិនប្រឈមនិងការស្លាប់ ឬការបាត់ បង់អវៈយវៈទេ តែជីវិតយើងនឹងផ្លាស់ប្រែ។ ព្រះគ្រីស្ទរំលឹកថា ការដើរតាមទ្រង់ មានន័យថា យើងបដិសេធន៍ខ្លួនឯង ហើយលីឈើឆ្កាង។ ដូច្នេះ ការប្រកាស ទទួលព្រះគ្រីស្ទ មានន័យថាយើងស្លាប់ពីការតូចៗជាច្រើន ដោយមិនគិតពីការចង់បានរបស់ខ្លួនឯង តែគិតពីអ្នកដទៃ ហើយបំរើជានិច្ច។ ក្នុងសម្បត់សមាជិកភាព របស់មេថូឌីស្ទយើង យើងតាំងចិត្តរស់នៅក្នុងពិធីជ្រមុជ នៃសេចក្ដីស្លាប់ និងការរស់ឡើងវិញ។

ប៉ុន្តែ យើងមិនអាចប្រកាស់ទទួលព្រះគ្រីស្ទ ដោយអំណាចខ្លួនឯងបានទេ។ ដូច្នេះ យើងសន្យាថានឹងទុកចិត្តព្រះគុណ ការអត់ទោស ការប្រោសអោយជា និងវត្តមានទ្រង់។ សំរាប់យូណៃធីតមេថូឌីស្ទ ការទុកចិត្តក្នុងព្រះគុណព្រះ តែងតែទាក់ទងនិងការតាំងចិត្ត ក្នុងការដើរតាម «វិធីនៃព្រះគុណ» កន្លែងដែលយើងអាចជួបព្រះ និងទទួលបានជំនួយតាមត្រូវការ។ លោក ចន វេស្លី បង្រៀនថា «អស់អ្នកដែលត្រូវការព្រះគុណព្រះ ត្រូវរងចាំរហូតទាល់តែទ្រង់ប្រទានឲ្យ ហើយនឹងប្រើព្រះគុណនេះ មិនមែនគ្រាន់តែយកមកទុកនោះទេ»[21]។ តាមលោក ចន វេស្លី ព្រះសន្យាថា នឹងជួប យើងពេលមានការប្រកបគ្នា ដោយព្រះបន្ទូល និងពិធីវិសុទ្ធ។ ព្រះជួបយើងពេលយើងអធិស្ឋាន និងពេលយើងសិក្សាព្រះគម្ពីរ។ ការតមអាហារ ក៏ជាវិធីមួយដែរ។ យើងមិនមែនទទួលព្រះគុណនេះដោយឯកឯងនោះទេ។ លោក វេស្លី ជឿលើសិរីភាព និងអធិបតេយ្យភាពរបស់ព្រះ មានន័យថាព្រះអាចមានទំនាក់ទំនងជាមួយយើង តាមការដែលទ្រង់ចង់បាន។ គាត់ក៏បានរំលឹកយើងថា សេចក្ដីស្រឡាញ់ គឺជាចុងបញ្ចប់ សំរាប់ព្រះគុណគ្រប់យ៉ាង ហើឲ្យយើងបើកចិត្ត សំរាប់ព្រះទ័យរបស់ព្រះ ចំពោះពិភពលោក។ យ៉ាងណាក៏ដោយ សេចក្ដីបញ្ចប់គឺច្បាស់ណាស់។ អ្នកដែល ចង់ទទួលបានព្រះគុណព្រះ ត្រូវប្រើវិធីទាំងអស់នេះ។[22]

---

[19] The Westminster Dictionary of Church History, edited by Jerald C. Brauer (Philadelphia: The Westminster press, 1971), ទំព័រ 537.

[20] Dietrich Bonhoeffer, The Cost of Discipleship (New York:  Simon and Schuster, 1995), 89.

[21] John Wesley, “The Means of Grace,” The Works of John Wesley, Volume 1, Sermons 1, 1-33, Albert C. Outler, editor (Nashville: Abingdon Press, 1984), page 384. សូមអានសៀវភៅវិន័យ, 2012, កថាខណ្ឌ104, ទំព័រ 77-78.

[22] Ibid., 378.

ការហៅឲ្យមនុស្សប្រើ វិធីនៃព្រះគុណ គឺដូចជាការរំលឹកឲ្យគេបរិភោគអាហារល្អៗ ហាត់ប្រាណ និងសំរាក។ យើងដឹងថា មនុស្សនឹងទទួលបានប្រយោជន៍ ពីការទាំងនេះ តែវាងាយក្នុងដែល យើងឈប់ធ្វើ ដោយការរវល់ការងារពេក ហើយចូលចិត្តតែអាហារមិនល្អ។ ដូចគ្នានេះដែរ គ្រីស្ទានភ្លេចពីប្រពភពនៃកំលាំងរបស់គេ ដែលបានមកពីព្រះបន្ទូល និងការប្រកបគ្នា តែគេ ចង់បានតែអាហារមិនល្អ ដែលមិន ស្របតាមព្រះគម្ពីរ និងវប្បធម៌លោកិយ។ ជួនកាលគេរវល់ ខ្លាំង ដោយមិនមានពេល បំប៉នខ្លួនឯងសោះ។ សម្បត់ឲ្យយើងទុកចិត្តព្រះគុណព្រះ រំលឹកឲ្យ យើង ទទួលអាហារខាងវិញ្ញាណឲ្យមានតុល្យភាព។

## តាំងចិត្តជាមួយក្រុមជំនុំ និងព្រះបន្ទូល



ការងារទាំងនេះត្រូវបានបញ្ចប់ ជាមួយរាត្រីនៃសេចក្តីសន្យា។ ជា គ្រីស្ទាន យើងមានគ្រួសារនៃសេចក្តី សន្យា ដែលជាក្រុមជំនុំ និងគ្រួសារ ជាច្រើនទៀតក្នុងព្រះគម្ពីរ។ យើង តាំងចិត្តរស់នៅជាមួយគ្រួសារនេះ។ សម្បត់ទី៤ និងទី៧ និយាយពី សន្យាទាំងនេះ។ សមាជិកយូណៃធី តមេថូឌីស្ទ តាំងចិត្តចំពោះការ ខាងក្រោមនេះ៖

ស្ម័គ្រស្មោះជាសមាជិកក្រុមជំនុំព្រះគ្រីស្ទ និងបំរើទ្រង់នៅក្នុងពិភពលោកនេះ។

ទទួលនិងប្រកាសសេចក្តីជំនឿគ្រីស្ទាន ដែលមានចែងក្នុងព្រះគម្ពីរ ទាំងសញ្ញាថ្មី និងសញ្ញាចាស់។[23]

ក្នុងសេចក្តីសន្យានៃពីធីជ្រមុជទឹក សម្បត់នៃសេចក្តីជំនឿតាមព្រះគម្ពីរ មានបន្ទាប់ពីសម្បត់នៃ សមាជិកស្មោះត្រង់។ សម្បត់ទាំងពីរនេះទាក់ទងគ្នាយ៉ាងជិតស្និទ។[24]

---

[23] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012, paragraph 217, ទំព័រ 153.

[24] សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, 34-35.

ក្រុមជំនុំជាគ្រួសាររបស់យើង ហើយយើងស្បត់ថានឹងថែរក្សាគ្រួសារយើង។ ជីវិតពិបាកណាស់ ហើយជួនកាលអ្នកដែលនៅជិតយើង ជាអ្នកបង្ករបញ្ហា។ ដូច្នេះ យើងអាចមានហេតុផលជាច្រើនដើម្បីបោះបង់ចោលគ្រួសារមួយនេះ។ ដូច្នេះហើយបានជាអាពាហ៍ពិពាហ៍ និងគ្រួសារត្រូវមានឫសគល់ពីសម្បត់៖

ទោះល្អ ឬអាក្រក់
ទោះមាន ឬក្រ
ទោះឈឺ ឬជា
ត្រូវស្រឡាញ់ និងថែរក្សា
រហូតដល់ស្លាប់រាងៗខ្លួន។[25]

ដូចសម្បត់ដទៃដែរ សម្បត់អាពាហ៍ពិពាហ៍ ចាក់ឫសក្នុងព្រះគុណព្រះ ហើយយើងជឿថា ឲ្យចំណុះ និងធ្វើអោយវាកាន់តែរីកចំរើន។ យើងត្រូវការសម្បត់បែបនេះ ដើម្បីអោយយើងមានការតាំងចិត្តខ្ពស់ ចំពោះក្រុមជំនុំ ហើយចងចាំ ពេលដែលយើងនិយាយពីក្រុមជំនុំ យើងនិយាយពីក្រុមជំនុំដែលយើងស្គាល់ ឃើញ ប៉ះ ឮ និងធំខ្លិន។ ពិតណាស់ មានពេលខ្លះក្រុមជំនុំមានខ្លិនល្អ ពេលខ្លះក៏មិនល្អដែរ។

អ្នកខ្លះអាចនិយាយថា ក្រុមជំនុំអាចលាក់កំពុត ហើយមិនបានមើលវែងឆ្ងាយ។ អ្នកខ្លះនិយាយក្រុមជំនុំធ្វើអោយមនុស្សមួយចំនួនឈឺចាប់ខ្លាំង។ គេនិយាយត្រូវ។ ក្រុមជំនុំមានបាប តែក៏មានពេញដោយព្រះគុណដែរ។ មានអ្នកខ្លះទទួចថា ពេលគេអង្គុយក្បែរទឹកហូរ ពួកគេមាន អារម្មណ៍ស្និតស្នាលជាមួយព្រះជាង ពេលដែលគេ មកថ្វាយបង្គំនៅថ្ងៃអាទិត្យ។ គ្មានអ្នកណាអាចប្រកែកចំនុចនេះបានទេ។ ការបើក សម្តែងខាងវិញ្ញាណខ្លះ ទាមទារឲ្យខ្ញុំចំណាយពេលម្នាក់ឯង តែសេចក្តីជំនឿ គ្រីស្ទាន មិនមែនបែបនេះទេ។ ព្រះក្នុងព្រះគម្ពីរ ធ្វើការជាមួយគ្រួសារ កុលសម្ព័ន ទោះជាគេមិនល្អអត់ខ្មោះក៏ដោយ។ ព្រះធ្វើការជាមួយក្រុមសាវក្ស ក្រុមជំនុំ សិស្សទាំង១២ ទាំង៧០ និង១២០ (លូកា ៩៖១-៦; ១០៖១-១២; កិច្ចការ ១៖១៥-២៦)។ ព្រះអម្ចាស់គឺតែ១ តែជាព្រះត្រ័យឯក ព្រះវបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ។

ដូច្នេះព្រះរបស់យើងជាព្រះសហគមន៍។ បើអ្នកចង់បានព្រះដែលមិនធ្វើការក្នុងក្រុម នោះអ្នកត្រូវតែស្វែងរកព្រះផ្សេងទៀត។ ព្រះដែលយើងអានក្នុងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ទាមទារឲ្យយើងតាំងចិត្តចំពោះរាស្ត្រនៃសេចក្តីសន្យារបស់ទ្រង់។

តើយើងបានប្រយោជន៍អ្វី ពីការតាំងចិត្តនេះ? ប្រយោជន៍ដែលសំខាន់បំផុតគឺវត្តមាន របស់ព្រះគ្រីស្ទដ៏មានព្រះជន្មរស់។ ទ្រង់បានសន្យាថា យើងនឹងស្វាគមន៍ទ្រង់ កណ្តាលចំណោម

---

[25] "កម្មវិធីអាពាហ៍ពិពាហ៍គ្រីស្ទបរិសុទ្ធ" សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, ទំព័រ 867, © 1989 រោងពុម្ពយូណៃធីតមេថូឌីស្ទ

អ្នកស្មោះត្រង់។ «កន្លែងណាដែលមានមនុស្សពីរឬបីនាក់ប្រជុំគ្នា នោះខ្ញុំនឹងនៅទីនោះ។» (ម៉ាថាយ ១៨៖២០)។ ក្រុមជំនុំជឿថា ដួងចិត្តរបស់គេមានភាពកក់ក្តៅ ពេលបានឮព្រះបន្ទូល (លូកា ២៤:៣២) គេស្គាល់ព្រះគ្រីស្ទ ពេលទ្រង់កាច់នំប៉័ង (លូកា ២៤៖៣៥)។ អាចកំបាំងនៃព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ ស្ថិតលើបងប្អូនប្រុសស្រីរបស់ខ្ញុំ។ គេឮពីការប្រកាសជំនឿរបស់ខ្ញុំ ហើយប្រកាសការអភ័យទោស របស់ព្រះ។ គេអោបខ្ញុំ គេសើច និងយំជាមួយខ្ញុំ ហើយព្រះប្រោសខ្ញុំអោយជា តាមរយៈគេទាំងអស់គ្នា។ ប្អូនប្រុសស្រីរបស់ខ្ញុំ ដឹងពីចំនុចខ្សោយរបស់ខ្ញុំ ដូច្នេះគេជួយស្អាងខ្ញុំ ប៉ុន្តែគេក៏ស្គាល់ពីចំនុចខ្លាំងរបស់ខ្ញុំ ដូច្នេះគេឲ្យខ្ញុំប្រើអំណោយទានរបស់ខ្ញុំ។ គេចែកចាយនូវបទពិសោធន៍ និងប្រាជ្ញារបស់គេ ហើយជួយបង្រៀនខ្ញុំ។ ខ្ញុំចង់ឲ្យគេមានការតាំងចិត្ត ចំពោះខ្ញុំ ហើយខ្ញុំក៏មានការតាំងចិត្តចំពោះគេដែរ។

ជីវិតក្នុងក្រុមជំនុំរបស់ពួកយើងទាំងអស់គ្នា ឲ្យយើងបន្តស្វែងយល់ពីព្រះបន្ទូល ទាំងសញ្ញាចាស់ និងសញ្ញាថ្មី។ ដូចដែលក្រុមជំនុំជាគ្រួសារត្រូវបានប្រទានមកឲ្យ យើង ព្រះគម្ពីរក៏បានប្រទានមកឲ្យយើងដែរ។ យើងអាចគិតថាព្រះគម្ពីរគឺជា កម្រងរូបភាពគ្រួសារ ដែលមានគ្រប់បែបផែន។ រឿងចោរ និងអ្នកកំផិត ក៏មានដែរ។ ជួនកាល ក្មេងដូច ស្តេចដាវីឌ ក៏អាចជាវិរៈបុរសបានដែរ។ ព្រះគម្ពីរ ឲ្យរឿងគោលមកយើង ហើយយើងដឹងថា ដែលយើងជាសមាជិកក្រុមជំនុំ នឹងមិនអាចយល់បានទេ លុះត្រាតែយើងស្គាល់ព្រះគម្ពីរ ហើយបន្តស្វែងយល់រហូត។ ដែល រឿងនិមួយៗ ជួយឲ្យយើងយល់ពីគ្រួសារនៃសេចក្តីសន្យា ក៏មិនមែនមានន័យថា រឿងទាំងអស់ សុទ្ធតែបង្ហាញពីអត្តសញ្ញាណរបស់យើងដែរ។

សេចក្តីប្រកាសជំនឿសាវក្ស ដែលជាគោលសំខាន់ក្នុង សេចក្តីសញ្ញានៃពិធីជ្រមុជ ដើរតួជាគោលការណ៍រៀបចំយ៉ាងសំខាន់។ ពេលយើងអញ្ជើញបេក្ខជនដែលត្រូវទទួលពិធីជ្រមុជទឹក និងចូលជាសមាជិក «អោយនិយាយជាមួយគ្នានូវការប្រកាសសេចក្តីជំនឿគ្រីស្ទបរិស័ទ ដែលមានចែងក្នុងព្រះគម្ពីរទាំងសញ្ញាថ្មី និងសញ្ញាចាស់។»[26] នោះយើងនឹងឆ្លើយដោយសេចក្តីប្រកាស។ ការធ្វើនេះ យើងធ្វើតាមគំរូសំណេរដែលមានឫសតាំងពីដើមមក។[27]

ការប្រើសេចក្តីសន្យា ដើម្បីឆ្លើយសំនួរអំពីរព្រះគម្ពីរ គឺជាវិធីសាស្ត្រឆ្លាតមួយ ព្រោះវារំលឹកយើងថា ព្រះគម្ពីរមិនមែនជាតារាងច្បាប់ ឬគោលការអំពីព្រះ ឬសេចក្តីសន្យាដែលនឹងត្រូវសំរេច ឬក៏មិនមែនជារឿងពីគ្រួសារ ឬមនុស្សណាម្នាក់នោះដែរ។ សេចក្តីសន្យា ជួយយើងឲ្យយល់ពីអ្វីដែលក្រុមជំនុំចាត់ទុកជាសំខាន់បំផុត អំពីរឿងរាវក្នុងព្រះគម្ពីរ។ ព្រះគម្ពីរជា សាក្សីនៃព្រះ ដែលសំដែងជាព្រះត្រ័យឯក គឺព្រះវបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ព្រះអម្ចាស់បាន

---

[26] សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, ទំព័រ 35. Baptismal Covenant I from Baptismal Covenants I, II ©1976, 1980, 1985, 1989, រោងពុម្ពយូណៃធីតមេថូឌីស្ទ.

[27] Paul F. Bradshaw, Maxwell E. Johnson, and L. Edward Phillips. The Apostolic Tradition, A Commentary. Edited by Harold W. Attridge (Minneapolis, Minnesota: Fortress Press, 2002), 114-17.

បង្កើតគ្រប់របស់ទាំងអស់។ បេះដូងនៃរឿងរាងក្នុងព្រះគម្ពីរ គឺជីវិត ការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ យើងទទួលបានជីវិត តាមរយៈព្រះគ្រីស្ទ ហើយពន្ធកិច្ចរបស់ទ្រង់បន្តនៅក្នុងក្រុមជំនុំ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ នេះហើយជាបេះដូងនៃរឿងរាវក្នុងព្រះគម្ពីរ។

សេចក្តីសន្យាមិនបានឆ្លើយគ្រប់ទាំងសំណួរនោះទេ។ វាមិនបានប្រាប់ថាយើងគួរធ្វើយ៉ាងម៉េចចំពោះភាវរៈកម្មអន្តរជាតិ ឬប្រពន្ធសុខាភិបាល ឬប្រពន្ធអប់រំនោះទេ។ វាមិនបាននិយាយពីការពន្លូតកូន ឬការរួមភេទដូចគ្នានោះដែរ។ វាក៏មិនបានប្រាប់ថា មនុស្សត្រូវទទួលពិធីជ្រមុជទឹកអាយុប៉ុន្មាន ឬត្រូវធ្វើបែបណាដែរ។ ព្រះគម្ពីរនិយាយថា ព្រះគ្រីស្ទនឹងយាងមកវិញ តែក៏មិនបានបញ្ជាក់ពីពេលណាដែរ។ យើងគួរតែពិភាក្សាពីការទាំងនេះដោយបើកគម្ពីរ និងការយកចិត្តទុកដាក់ ហើយជាយូណៃធីតមេថូឌីស្ទ យើងប្តេជ្ញាចិត្តធ្វើការទាំងនេះ។ យើងគួរបន្ថយកសំនួររបស់យើង ទៅព្រះគម្ពីរ ទោះបីជាភាគច្រើនយើងមិនទទួលបានចំលើយទេ តែទទួលបានសំនួរមកវិញ។ ទោះបីជាយើងធ្វើការពិភាក្សា យ៉ាងណាក៏ដោយ យើងត្រូវចាំថា បេះដូងនៃព្រះគម្ពីរ។ សេចក្តីសន្យា ដែលគ្រីស្ទបរិសទ្ធជុំវិញពិភពលោកប្រកាស រំលឹកយើងថា ទោះបីជាយើងខុសគ្នាក៏ដោយ ក៏យើងមានចំនុចរួម ពីការប្រកាសរបស់ក្រុមជំនុំ។

យើងបានពិភាក្សាពីសម្បត់ និងការប្តេជ្ញាចិត្ត ដែលដូចគ្នានិងក្រុមជំនុំក្នុងពិភពលោក។ ពេលនេះ សូមយើងបែរចំណាប់អារម្មណ៍របស់យើង ទៅការប្តេជ្ញាចិត្ត ដែលទាក់ទងនិងការត្រាស់ហៅមកក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ និងជាសមាជិកនៃក្រុមជំនុំតំបន់។ សម្បត់ទី៥ និងទី៦ និយាយពីការនេះ។

# សម្បត់ដែលទាក់ទង និងការត្រាស់ហៅ ជាក់លាក់របស់យើង

## ការត្រាស់ហៅមកបម្រើជាយូណៃធីតមេថូឌីស្ទ

សមាជិកយើង តាំងចិត្ត «ស្មោះស្ម័គ្រចំពោះព្រះគ្រីស្ទ តាមរយៈក្រុមជំនុំយូណៃធីតមេថូឌីស្ទ ហើយធ្វើអស់ពីកំលាំងដើម្បីពង្រឹងពន្ធ័កិច្ចក្រុមជំនុំ។»[28] សូមចំណាំពីការកែប្រែដែលមានក្នុងសៀវភៅចំរៀងយូណៃធីតមេថូឌីស្ទ[29] ដោយមានភាសាថ្មី ដែលបានសំរេចដោយ មហាសន្និបាតសកលលោកឆ្នាំ២០០៨។ ពីមុនសមាជិកសន្យាស្មោះស្មគ្រ័ជាមួយក្រុមជំនុំយូណៃធីត មេថូឌីស្ទ ពេលនេះយើងសន្យាស្មោះស្មគ្រ័ជាមួយព្រះគ្រីស្ទ តាមរយៈនិកាយរបស់យើង។ ភាសានេះផ្តល់ការបញ្ជាក់យ៉ាងសំខាន់ ហើយយើងគួរប្រើវា។ វាជាប្រយោគដែលខ្លាំង ហើយជាក់លាក់។

ដូចដែលយើងបានដឹង សេចក្តីជំនឿគ្រីស្ទបរិសទ្ធ បង្ហាញតាមក្រុមជំនុំដទៃៗជាច្រើន។ គ្រប់គ្នាជាសាក្សីនៃសេចក្តីពិត ដូចដែលគេបានឃើញក្នុងព្រះគ្រីស្ទ ហើយគ្រប់គ្នា ចង់បំរើព្រះអម្ចាស់ដោយអំណាចនៃព្រះវិញ្ញាណ។ គ្រប់គ្នាឆ្លើយតបនិងការក្រើនរំលឹករបស់សាវក្សប៉ុល ដែលសរសេរថា «ចូរបង្ហើយសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នា ដោយកោតខ្លាច ហើយញាប់ញ័រចុះ... ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណងចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហរទ័យទ្រង់ដែរ។» (ភីលីព ២៖១២-១៣)។ និកាយនិមួយៗ មានអំណោយទាន និងការត្រាស់ហៅរាងៗខ្លួន។ ដូចជាមនុស្សយើងម្នាក់ៗ ក្រុមជំនុំក៏ដូចគ្នាដែរ។ ព្រះប្រទានព្រះគុណដល់អ្នកគ្រប់គ្នា តែគ្មានអ្នកណាដែលល្អឥតខ្ចោះទេ។ ដូច្នេះវាជាការសំខាន់ណាស់ ដែលក្រុមជំនុំត្រូវសន្ទនា រៀន និងអធិស្ឋានជាមួយគ្នា។ ខ្ញុំបានរៀនមេរៀនសំខាន់មួយអំពីការថ្វាយបង្គំពីមិត្តភក្រ័មកពី ក្រុមជំនុំ Episcopal និង Pentecostals។ ខ្ញុំបានរៀនពីពិធីជ្រមុជ និងគោលការណ៍គ្រីស្ទាន តាមរយៈបងប្អូន កាតូលិក បាបទីស្ទ មេណូណៃ និងលូថារិន។ ក្រៅពីអ្នកណែនាំ មេថូឌីស្ទរបស់ខ្ញុំ ខ្ញុំរៀនពីការអធិប្បាយពីគ្រូម្នាក់មកពី ប្រេបីថេរៀន និងរៀនពីមិត្តម្នាក់មកពីសហពន្ធ័បាបទីស្ទជាតិ។ ការទាក់ទងទាំងនេះ វាមានតំលៃណាស់ ហើយខ្ញុំសង្ឃឹមថា រង្វង់នៃមិត្តភក្រ័អន្តរនិកាយរបស់ខ្ញុំ នឹងធ្វើអោយខ្ញុំកាន់តែប្រសើរឡើង។

---

[28] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012, កថាខណ្ឌ 217, ទំព័រ 153. ប្រើដោយមានការអនុញ្ញាតិ។ សំរាប់ការប្រើក្នុងកម្មវិធីរបស់យើង សូមមើល «សម្បត់និងកម្មវិធីសមាជិកភាពថ្មី (កែសម្រួលឡើងវិញ)» http://www.gbod.org/lead-your-church/membership/resource/new-membership-vows-and-ritual-revised-and-corrected Accessed August 29, 2013.

[29] ភាសាដើមគឺ «ជាសមាជិកក្រុមជំនុំសកល តើអ្នកនឹងស្ម័គ្រស្មោះចំពោះក្រុមជំនុំយូណៃធីតមេថូឌីស្ទ ហើយធ្វើគ្រប់យ៉ាងដើម្បីពង្រឹងពន្ធកិច្ចរបស់ក្រុមជំនុំដែរឬទេ?» សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, 38.

ទោះជាយ៉ាងណាកដោយ មនុស្សម្នាក់មិនអាចជាសមាជិកក្រុមជំនុំពីរបីបានទេ តែយើងម្នាក់ៗ មានអត្តសញ្ញាណនិកាយមួយ។ យើងជាយូណៃធីតមេថូឌីស្ទ យើងបំរើព្រះគ្រីស្ទតាមរយៈ ក្រុមជំនុំ។ អត្តសញ្ញាណនេះគឺជាអំណោយទាន សំរាប់មិត្តភក្រ័អន្តរនិកាយរបស់យើង។



ពេលយើងសន្យាថាស្មោះស្មគ្រ័ចំពោះព្រះគ្រីស្ទ តាមរយៈក្រុមជំនុំយូណៃធីតមេថូឌីស្ទ យើង មិនបាននិយាយថា ក្រុមជំនុំរបស់យើង ល្អជាងគេទេ ឬក៏យើងមានគំនិតមិនចុះចូលជាមួយ អ្នកណាទេ។ ហើយយើងក៏មិននិយាយថា គ្រប់គ្នាដែលនៅជិតខាងយើងគួរក្លាយជាមេថូឌីស្ទ ទាំងអស់នោះដែរ។ យើងសប្បាយចិត្ត ពេលគេចូលរួមថ្វាយបង្គំជាមួយយើង ហើយយើងក៏ គួរតែសប្បាយចិត្តដែរ ពេលដែលអ្នកណាម្នាក់ ឆ្លើយតបនិងការត្រាស់ហៅរបស់ព្រះ ដើម្បីបំរើ ដោយស្មោះស្មគ្រ័ ជាប្រេសបីថេរៀន ជាកាតូលិក ឬជាសមាជិករបស់និកាយ Assemblies of God។ សម្បត់ពីការស្មោះស្មគ្រ័ចំពោះព្រះគ្រីស្ទ តាមរយៈក្រុមជំនុំយូណៃធីតមេថូឌីស្ទ មិនបាន និយាយពីភាពអវិជ្ជមានរបស់និកាយផ្សេងនោះទេ។ វាជាការដែលយើងទទួលស្គាល់ថា ក្រុមជំនុំ យូណៃធីតមេថូឌីស្ទ ជាកន្លែងល្អបំផុតសំរាប់យើងរស់នៅ សំរាប់ការប្តេជ្ញាចិត្តចំពោះព្រះ។ យើង ទទួលស្គាល់ការត្រាស់ហៅរបស់ព្រះសំរាប់ជីវិតយើង ដែលជាផ្នែកមួយនៃក្រុមជំនុំ។ ការរស់នៅ ជាសិស្សរបស់ព្រះគ្រីស្ទ តាមរយៈក្រុមជំនុំយូណៃធីតមេថូឌីស្ទ មានន័យថា យើងគាំទ្រប្រពន្ធ័ ទាក់ទងគ្នា នៃការធ្វើការ និងបេសកកម្ម។ យើងមិនមែនគិតថាខ្លួនឯង ដាច់ដោយឡែកពី ក្រុមជំនុំទេ តែយើងជាក្រុមជំនុំដែលបើកសម្តែងបរិបទផ្សេងៗ។ ការរួបរួម មិនមែនមានន័យថា យើងត្រូវតែដូចគ្នាទាំងស្រុងនោះទេ ដូចជាភោជនីដ្ឋានផ្សេងៗ អញ្ចឹងដែរ។ តែយើងជឿថា យើងរួមគ្នាក្នុងព្រះគ្រីស្ទ ក្នុងការយល់ពីព្រះគុណរបស់ព្រះ និងទម្រង់បែបបទ នៃក្រុមជំនុំ។ យើងទាក់ទងគ្នា សំរាប់បេសកកម្មក្នុងសហគមន៍ និងក្នុងពិភពលោក ដែលមានន័យថាយើងនិង អ្នកផ្សេងទៀតគឺជាសិស្សរបស់ព្រះគ្រីស្ទ។ សូមនឹកចាំពីសម្បត់ ដែលថាយើងស្មោះស្មគ្រ័ចំពោះ ព្រះគ្រីស្ទ តាមរយៈក្រុមជំនុំ ដើម្បីពង្រឹងពន្ធ័កិច្ចរបស់ក្រុមជំនុំ។

ក្នុងនាមជាអេលដឺ (Elder) ក្នុងក្រុមជំនុំនេះ ការស្មោះស្មគ្រ័ចំពោះព្រះគ្រីស្ទ តាមរយៈក្រុមជំនុំ យូណៃធីតមេថូឌីស្ទ មានន័យថា ខ្ញុំយល់ព្រមធ្វើការតាមប្រពន្ធ័ផ្លាស់ប្តូគ្រូគង្វាល

ដែលមានន័យថាខ្ញុំ នឹងពិភាក្សាជាមួយលោកអភិបាល និងអ្នកផ្សេងទៀត ពីតួនាទីរបស់ខ្ញុំ ហើយទុកចិត្តការ យល់ដឹងរបស់ក្រុមជំនុំ ទាក់ទងនិងក្រុមជំនុំណាដែលខ្ញុំអាចបំរើបានល្អបំផុត។[30] ផ្នែកមួយនៃក្រុមជំនុំរបស់ព្រះគ្រីស្ទ ខ្ញុំនឹងរៀនពីប្រវត្តិរបស់វា និងធ្វើអោយល្អបំផុតក្នុងការអនុវត្តន៍ព្រះគុណ និងសេចក្តីមេត្តាករុណា របស់ព្រះ។ ខ្ញុំនឹងរៀនពីការពន្យល់ព្រះគម្ពីរពីលោក ចន វេស្លី និងអនុវត្តន៍ការបង្កើតសិស្ស។ ខ្ញុំនិងរៀនចំរៀងរបស់លោក ឆាល វេស្លី ជាយូណៃធីតមេថូឌីស្ទខ្ញុំនឹងរៀនពីគោលលិទ្ធិរបស់ក្រុមជំនុំនិងខំធ្វើតាមគោលការណ៍សង្គម។ខ្ញុំនឹងប្រើពិធីការរបស់ក្រុមជំនុំ។ ខ្ញុំនឹងធ្វើពិធី លៀងព្រះអម្ចាស់ ហើយពេលខ្ញុំរៀបចំពិធីលៀងព្រះអម្ចាស់ ខ្ញុំនឹងប្រើទឹកទំពាំងបាយជូ។ ខ្ញុំប្រហែលជាមិនយល់ស្របតាមគំនិតរបស់ក្រុមជំនុំទាំងអស់នោះទេ តែពេលដែលខ្ញុំមិនយល់ស្រប ខ្ញុំនឹងធ្វើដោយការគោរព ហើយនឹងប្រើវិធីល្អៗដើម្បីកែប្រែ។ សំរាប់ប្រយោជន៍របស់ព្រះគ្រីស្ទ និងដំណឹងល្អ ខ្ញុំនឹងធ្វើគ្រប់ការទាំងអស់ ដើម្បីពង្រឹងពន្ធកិច្ចរបស់ក្រុមជំនុំយូណៃធីតមេថូឌីស្ទ អោយបានរីកលូតលាស់។

តាមគំនិតអន្តរនិកាយ ពាក្យថាស្មោះស្មគ្រ័ចំពោះព្រះគ្រីស្ទ តាមរយៈនិកាយរបស់យើង ដូចជាមិនសូវសម។ ឧទាហរណ៍ នេះមិនមែនជាពិធីការរបស់និកាយបងប្អូនយើង គឺ Episcopal Church[31] អត្ថន័យ និងសារៈសំខាន់អន្តរនិកាយ នៃក្រុមជំនុំយូណៃធីតមេថូឌីស្ទ មានបើកសម្តែងក្នុងបរិបទប្រវត្តិសាស្ត្រ។ លំនាំតាមវិធីមេថូឌីស្ទពីមុន ដូចដែលមានក្នុងទំរង់ចាស់ដែរ ដែលចែងថា «តើអ្នកនឹងស្មគ្រ័ស្មោះចំពោះនិកាយមេថូឌីស្ទ ហើយគាំទ្រនិកាយនេះដោយការអធិស្ឋាន វត្តមាន អំណោយទាន និងការបំរើ ដែរឬទេ?» ដែលទំរង់នេះមានក្នុងសៀវភៅចំរៀង តាំងពីសតវត្សទី២០។[32] វាបង្ហាញពីឫសគល់នៃការផ្ទុយពីវប្បធម៌របស់និកាយមេថូឌីស្ទ ដែលជាការរំលឹកមួយថា ចលនារបស់លោកវេស្លី ចាប់ផ្តើមជាសង្គមមួយក្នុង ក្រុមជំនុំប្រទេសអង់គ្លេស។ វាជាចលនាមួយដែលមានការតាំងចិត្តខ្ពស់ ផ្សារផ្ជាប់ជាមួយ រចនាសម្ពន័សាសនា ដែលមានចេតនារិះគន់ និងស្ថាបនាក្រុមជំនុំ។ អ្នកចូលរួមដោយឆន្ទៈ ដោយការតាំងចិត្ត ដែលមានចែងក្នុងក្រុមជំនុំ។ ក្នុងសម័យលោកវេស្លី គ្រប់គ្នាត្រូវធ្វើតាមគោលការណ៍ និងច្បាប់ទូទៅរបស់ក្រុម។ ពេលដែលវាពិតតាមឫសគល់ និកាយមេថូឌីស្ទ គឺជាចលនាដែលមានការតាំងចិត្តខ្ពស់។ សម្បត់នេះរំលឹកយើងពីការរំពឹងទុកយ៉ាងខ្ពស់។ បើសិនជា និកាយយូណៃធិតមេថូឌីស្ទ រួមជាមួយនិកាយក្រុមជំនុំអង់គ្លេស ឬរ៉ូមិនកាតូលិក នោះគំនិតដែលថាក្រុមជំនុំមួយធ្វើផ្ទុយពីវប្បធម៌នៃបេសកកម្ម គឺជាអំណោយទានសំខាន់ បំផុតសំរាប់ក្រុមជំនុំទាំងមូល។

---

[30] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012, កថាខណ្ឌ 425-28, ទំព័រ 337-42.

[31] សូមមើលសៀវភៅអធិស្ឋានរួម (New York: The Church Hymnal Corporation, 1979), ទំព័រ 310, 418.

[32] សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, 1905, Psalter and Ritual section, ទំព័រ 94. សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, 1939, ទំព័រ 543. សៀវភៅថ្វាយបង្គំ, 1944, ទំព័រ 402. សៀវភៅថ្វាយបង្គំ, 1964, ទំព័រ 13.សៀវភៅចំរៀង, 1966, ទំព័រ 829-6. សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, 1989, ទំព័រ 38 and 48. សៀវភៅថ្វាយបង្គំ, 1992, ទំព័រ 93 and 109.

អ្នកខ្លះឆ្ងល់ថា តើការស្មោះស្មគ្រ័ចំពោះព្រះគ្រីស្ទ តាមរយៈក្រុមជំនុំយូណៃធីតមេថូឌីស្ទ មានន័យថាគេត្រូវតែនៅជាយូណៃធីតមេថូឌីស្ទ អស់មួយជីវិត។ មិនអញ្ចឹងទេ។ វាមានន័យថា គេត្រូវតែតាំងចិត្តរស់នៅជាគ្រីស្ទបរិសទ្ធក្នុងនិកាយយូណៃធីតមេថូឌីស្ទ កាន់តែយូរ កាន់តែប្រសើរ។ ពិតណាស់ យើងជឿថាព្រះមានអំណាចលើគ្រប់ទាំងអស់
ហើយក្នុងការគោរពចំពោះអំណាចនេះ យើងមិននិយាយថា យើងគោរពបានតែ៥ឆ្នាំ ឬ១០ឆ្នាំ ឬ២០ឆ្នាំនោះទេ។ មានតែព្រះទេ ដែលដឹង។
ខ្ញុំអាចសំរេចចិត្តថាថ្ងៃណាមួយព្រះត្រាស់ហៅអោយខ្ញុំបំរើព្រះ ក្នុងនិកាយផ្សេងមួយទៀត។ សម្បត់នេះមិនបានបំភ្លេចចំនុចមួយនេះទេ។ ខ្ញុំសង្ឃឹមថា វាជួយមិនឲ្យខ្ញុំសំរេចចិត្តដើរចេញយ៉ាងប្រញ៉ាប់ ដោយសារកំហឹង ឬការខកចិត្តណាមួយ។ ប៉ុន្តែ បើខ្ញុំបានគិតយ៉ាងច្បាស់ថានិកាយយូណៃធីតមេថូឌីស្ទ មិនមែនជាកន្លែងដែលខ្ញុំបំរើព្រះគ្រីស្ទទេ នោះខ្ញុំនឹងដកខ្លួនចេញពីសម្បត់នេះដោយសន្តិភាព។ ទោះបីជាខ្ញុំដកខ្លួនចេញក៏ខ្ញុំនៅតែគាំទ្ររពន្ធ័កិច្ចរបស់ក្រុមជំនុំយូណៃធីតមេថូឌីស្ទ ដោយមិនធ្វើការអាក្រក់ ហើយទទួលស្គាល់ថា ក្រុមជំនុំនេះជាកន្លែងដែលកំពុងធ្វើការព្រះ។

# ការត្រាស់ហៅមកបម្រើព្រះគ្រីស្ទ ជាសមាជិកនៃក្រុមជំនុំក្នុងតបន

សមាជិកក្រុមជំនុំយូណៃធីតមេថូឌីស្ទតាំងចិត្ត «ចូលរួមដោយស្មោះស្មគ្រ័ក្នុងពន្ធ័កិច្ចដោយសេចក្តីអធិស្ឋាន វត្តមាន អំណោយទាន ការបំរើ និងជាស្មរបន្ទាល់។»[33] ក្នុងពិធីជ្រមុជទឹក សម្បត់នេះត្រូវបានប្រើសំរាប់ទទួលនណាម្នាក់ចូលជាសមាជិកក្រុមជំនុំ[34] ហើយយើងនឹងពិភាក្សាពីសម្បត់នេះ ក្នុងបរិបទក្រុមជំនុំ។ ដូចជាសម្បត់ពីមុន ទម្រង់ដែលមាន «ជាស្មរបន្ទាល់» គួរត្រូវបានប្រើប្រាស់ ពេលប្រារព្ធពិធីនេះ។[35]

សម្បត់នេះមានភាពជាក់លាក់មួយ ដែលជាជំហានបន្ទាប់ដោយស្នើរអោយ គ្រីស្ទបរិសទ្ធមានការតាំងចិត្តរស់នៅ ក្នុងក្រុមជំនុំតំបន់មួយ។ ដោយព្រះគុណរបស់ព្រះ យើងកាន់តែខិតជិត

---

[33] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012, កថាខណ្ឌ 217, ទំព័រ 153. ប្រើដោយមានការអនុញ្ញាតិ.

[34] សៀវភៅចម្រៀងយូណៃធីតមេថូឌីស្ទ, ទំព័រ 38.

[35] «សម្បត់និងកម្មវិធីសមាជិកភាពថ្មី (កែសម្រួលឡើងវិញ)» http://www.gbod.org/lead-your-church/membership/resource/new-membership-vows-and-ritual-revised-and-corrected Accessed August 29, 2013.

ព្រះ «ឆ្ពោះទៅរកភាពល្អឥតខ្ចោះ»[36] ដោយសំណាញ់នៃទំនាក់ទំនង បញ្ហា និងប្រណាំងប្រជែង។ ពាក្យរបស់លោកវេស្លីដែលល្បីមួយ «ខ្ញុំចាត់ទុកពិភពលោកជាក្រុមជំនុំរបស់ខ្ញុំ»[37] ចង់បង្ហាញពីទំនាក់ទំនងរបស់គាត់ ទៅការងារផ្សាយដំណឹងល្អ ទៅដល់ស្នូរបន្ទាល់គ្រីស្ទបរិសទ្ធ ដ៏ច្រើនផ្សេងទៀត។ ប៉ុន្តែ គាត់មិនដែលចង់ បដិសេធន៍ទំនាក់ទំនង និងការទទួលខុសត្រូវ ដែលមានក្នុងជីវិតក្រុមជំនុំក្នុងតំបន់នោះទេ។

ជីវិតគ្រីស្ទបរិសទ្ធ ទាក់ទងទៅនិងការតាំងចិត្តច្បាស់លាស់។ ជាគ្រីស្ទបរិសទ្ធ យើងទទួលបានការត្រាស់ហៅឲ្យស្រឡាញ់ព្រះ និងអ្នកជិតខាង។ យើងជឿថាព្រះត្រាស់ហៅយើងឲ្យ «ធ្វើអំពើយុត្តិធម៌ និងស្រឡាញ់ភាពសប្បុរស» (មីកា ៦៖៨). ការដែល លោកម៉ាទីន លូធើឃីង សុបិន្ត ពីភាពស្មើរគ្នារវាងពរ៌សម្បុរ ធ្វើអោយ ប៉ះពាល់ចិត្តយើងណាស់។ យើងប្រហែលជា និយាយពីសេចក្ដីត្រូវការអោយក្រុមជំនុំយើងមានការរាក់ទាក់ និងបើកចំហរដល់មនុស្ស គ្រប់គ្នា។ ជាគ្រីស្ទបរិសទ្ធដែលរស់នៅ និងធ្វើការនៅកន្លែងមួយ យើងបានឃើញការតាំងចិត្ត ទាំងនេះជាក់ច្បាស់។ សាកស្រម័យមើលថាមានមនុស្សម្នាក់ដែលជិះកៅអីកង់ជនពិការ ហើយចង់មកថ្វាយបង្គំក្នុងព្រះវិហារយើង។ ប្រហែលគាត់ធ្លាប់មករួចហើយ ប៉ុន្តែមានបញ្ហាមួយ។ អ្នកជឿលើការរាក់ទាក់ ប៉ុន្តែព្រះវិហាររបស់អ្នកមានជណ្ដើរច្រើន ហើយបន្ទប់ទឹករបស់អ្នកមិនអាចដាក់កៅអីកង់ជនពិការបាន។ ការចូលរួមរបស់គាត់ធ្វើឲ្យយើងបន្ទាបខ្លួន ហើយគួរឲ្យខ្លាចទៀតផង។ វាមិនមែនជាការងាយស្រួលក្នុងការធ្វើឲ្យក្រុមជំនុំយើង មានការរាក់ទាក់ ដូចជាក្រុមជំនុំដែលអ្នកចូលរួមកាលពីវិស្សមកាលលើកមុន ព្រោះពេលនេះអ្នកដឹងថា ក្រុមជំនុំរបស់អ្នកមានបញ្ហាជាមួយការរាក់ទាក់។

តើអ្នកធ្វើយ៉ាងម៉េច? អ្នកចាប់ផ្ដើមការប្រជុំមួយ ហើយអ្នកពិភាក្សាបញ្ហានេះ។ អ្នកដឹងថាការដែលយើងធ្វើឲ្យព្រះវិហាររបស់យើង មានភាពងាយស្រួលដល់ជនពិការ វាត្រូវការ ចំណាយថវិការ និងពេលវេលាច្រើន។ ប្រធានសមាជិកអ្នកនិយាយថា «សន្និបាទប្រចាំឆ្នាំ ចង់អោយក្រុមជំនុំយើងមានភាពបើកចំហរ។ ប្រហែលគេមានថវិការផ្ដល់ឲ្យយើងធ្វើការនេះខ្លះ។» ម្នាក់ទៀតស្នើរឲ្យមានការស៊ើបមើលពត៌មាននេះ។ ពេលប្រជុំបន្ទាប់ គាត់រាយការណ៍ថា មានថវិការខ្លះសំរាប់ការនេះ តែមានតិចទេ មិនអាចសង់ជំរាល ឬជណ្ដើរយន្តបានទេ។ បញ្ហានេះពិបាកណាស់។ ពេលនោះដែរ ស្រីពិការនោះកាន់តែចូលរួមសកម្មភាពជាមួយ ក្រុមជំនុំយ៉ាងច្រើន។ អ្នកគិតថា ប្រហែលមានជនពិការផ្សេងទៀត ដែលចង់មកក្រុមជំនុំរបស់អ្នក ប៉ុន្តែគេមិនអាចមកបាន ដោយសារក្រុមជំនុំនុំរបស់អ្នកមិនមានលក្ខណៈងាយស្រួលដល់ពួកគេ។

---

[36] សៀវភៅវិន័យក្រុមជំនុំយូណៃធីតមេថូឌីស្ទ 2012, កថាខណ្ឌ 330.5.d (2), ទំព័រ 250. ប្រើដោយមានការអនុញ្ញាតិ.

[37] John Wesley, “Journal from August 12, 1738 to November 1, 1739” in The Works of John Wesley, Volume 1 (Zondervan Publishing House, reproduced from an 1872 edition), page 201.

ចុងក្រោយ អ្នក និងសមាជិកក្រុមជំនុំ ដឹងថាគ្មានអ្នកណាម្នាក់អាចជួយអ្នកបានទេ។ សេចក្តីត្រូវការនេះ នៅចំពោះមុខអ្នក ហើយព្រះត្រាស់ហៅ ឲ្យអ្នកដោះស្រាយបញ្ហានេះ។ មើលទៅអំណោយថវិការនិងបានមកពីសមាជិកដែលមកប្រជុំក្រុមប្រឹក្សា ដែលបោះឆ្នោតគាំទ្រ ការងារមួយនេះ។ មានក្រុមជំនុំច្រើនណាស់ ដែលមានបញ្ហាដូចដែលខ្ញុំបានបរិយាយ ឬក៏បញ្ហាប្រហាក់ប្រហែល។ ពេលនោះ គេសំរេចចិត្តធ្វើការត្រឹមត្រូវ ដោយសារព្រះគុណរបស់ ព្រះ។ គេបានបង្កើតកម្មវិធីមតេយ្យសាលា និងពន្ធ័កិច្ចផ្សេងទៀត សំរាប់កុមារៗនៅក្នុងភូមិ។ គេបង្កើតកម្មវិធីសិក្សាព្រះគម្ពីរសំរាប់យុវជន និងមនុស្សពេញវ័យ ក្រុមលើកទឹកចិត្តសំរាប់ អ្នកលេងលះគ្នា និងអ្នកដែលបាត់បង់សមាជិកគ្រួសារ ហើយគេបង្កើតការថ្វាយបង្គំមួយថ្មី សំរាប់អ្នកដែលមិនចូលចិត្តព្រះវិហារ។ ព្រះវិញ្ញាណបរិសុទ្ធបានបណ្តាលឲ្យក្រុមជំនុំ ធ្វើការងារជាច្រើន ហើយមានក្រុមជំនុំច្រើនឆ្លើយតបដោយសេចក្តីជំនឿ ដែលជាសាក្សីចំពោះ សេចក្តីមេត្តាករុណា និងយុត្តិធម៌របស់ព្រះ។ ជាមួយនិងសម្បត់ដទៃទៀត សម្បត់មួយនេះ ជួយគាំទ្រក្រុមជំនុំក្នុងតំបន់ច្រើន ហើយរំលឹកយើងថា វាលបេសកកម្ម ចាប់ផ្តើមក្នុងភូមិយើង។

ពិតណាស់ វាមិនមែនតែប៉ុណ្ណឹងទេ។ សាក្សីរបស់គ្រូគង្វាលមេថូឌីស្ទដំបូង ដឹងច្បាស់ថា ពួកគាត់ប្រកែកដាច់ខាតចំពោះការមើលឃើញខ្លីបែបនេះ។ សេចក្តីត្រូវការនៅក្នុងភូមិរបស់យើងមិនបានផ្តល់ជាបណ្ណ័បញ្ជាក់អោយយើងមើលរំលងមេរោគអេដស៍ នៅអាហ្វ្រិក និងអ្នកដែលត្រូវការមុងការពារជំងឺគ្រុនចាញ់ និងការឈឺចាប់របស់ជនភាសខ្លួននៅ មជ្ឈឹមបូពា និងគ្រប់អ្នកដែលគ្មានការធានារាប់រងសុខភាព និងអ្នកផ្សេងទៀតដែលមិនទាន់ បានឃើញ និងបានឮដំណឹងល្អ។ ប៉ុន្តែ សេចក្តីត្រូវការទាំងនេះអាចដោះស្រាយបាន តាមក្រុមជំនុំក្នុងតំបន់។ ថវិការនិងសំភារៈអាចផ្ញើរ ច្បាប់អាចសំរេច ប៉ុន្តែការដែលសំខាន់បំផុត គឺត្រូវមាន នណាម្នាក់ចេញទៅតំណាងក្រុមជំនុំ អធិស្ឋាន បង្ហាញវត្តមាន ផ្តល់អំណោយទាន ការបំរើ និងជាធ្វើសាក្សី។ សម្បត់ក្រុមជំនុំយូណៃធីតមេថូឌីស្ទ ហៅឲ្យយើងពិចារណាថា ពិភពលោកជាក្រុមជំនុំរបស់យើង ម្តងមួយៗ។

# សំរាប់ការអានផ្សេងទៀត

*Accountable Discipleship, Living in God's Household*, by Steven W. Manskar (Discipleship Resources, 2000)

*Baptism, Christ's Act in the Church*, by Laurence Hull Stookey (AbingdonPress, 1982).

"By Water and the Spirit, A United Methodist Understanding of Baptism," *The Book of Resolutions of The United Methodist Church*, 2012 (The United Methodist Publishing House, 2012), 922-42.

*Come to the Waters, Baptism and Our Ministry of Welcoming Seekers and Making Disciples*, by Daniel T. Benedict, Jr. (Nashville: Discipleship Resources, 1996).

*Sacraments and Discipleship, Understanding Baptism and the Lord's Supper in a United Methodist Context*, by Mark W. Stamm (OSL Publications, 2013; originally published by Discipleship Resources in 2001)

*The Cost of Discipleship*, by Dietrich Bonhoeffer (New York: Collier Books, 1959).

*The Early Methodist Class Meeting*, by David Lowes Watson (Nashville: Discipleship Resources, 1992).

# អំពីអ្នកនិពន្ធ

Mark W. Stamm ទទួលបានសញ្ញាបត្រ័បណ្ឌិតផ្នែកទេវវិទ្យា ពីសកលវិទ្យាល័យបុសស្តុន (University of Boston) និងជាសាស្ត្រាចារ្យផ្នែកការថ្វាយបង្គំគ្រីស្ទបរិសទ្ធ នៅសាលាទេវសាស្ត្រភឺគីន នៃសកលវិទ្យាល័យមេថូឌីស្ទខាងត្បូង (Perkins School of Theology, Southern Methodist University). លោកបណ្ឌិត **Stamm** ជាអេលឌឺ (Elder) នៃនិកាយយុណៃធីតមេថូឌីស្ទ និងជាសមាជិកនៃមហាសន្និបាទប្រចាំឆ្នាំតិចសាសខាងជើង។

1908 Grand Avenue
Nashville, TN 37212
UMCdiscipleship.org
877.899.2780

DISCIPLESHIP MINISTRIES
The United Methodist Church